## ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៤ ១១ មីនា ២០១៩

### យុវជន ឡៀង ធន

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យ មេសាង ខេត្តព្រៃវែង*

**ចំណងជើងកំណាព្យ៖ «ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- ចាប់ផងប៉ាកាចារសម្តែង រៀបរាប់ថ្លាថ្លែងបែងសេចក្តី
ជាកាព្យជាកេរស្មើរជាន់ថ្មី លំឱនវចីស្តីដើមដាន។

២- ឃ្លោងឃ្លាលើកដាក់អភិប្រាយ បទបរិយាយស្រាយលំអាន
លម្អិតសារៈតថៈថ្កាន កើតពីអំណានបានថ្លៃថ្លា។

៣- អានបានចំណេះចេះចំណាប់ គម្ពីរក្បួនច្បាប់ប្រាប់អាត្មា
អាត្ម័នឡើងខ្ពស់ព្រោះប្រាជ្ញា អានបានវោហារថាប្លែកៗ។

៤- អានឱ្យគ្រប់មុខរុករិះរក អានអាចនាំមកបាត់អល់អែក
អានមិនបង្អង់រង់ចាំស្អែក អានបានបំណែកបំណិនថ្មី។

៥- អានជាក់ជាគ្រឹះឫសគល់ពិត ប្រាជ្ញប្រាយបណ្ឌិតព្រឹទ្ធករី
សុទ្ធសឹងប្រឹងអានប្រាណឃ្នាតខ្មី ឥតប្រអូសអ្វីស្តីសច្ចៈ។

៦- អានជាកម្រាលក្រាលដោយមាស ល្អល្អះឱភាសពាសសារៈ
សង្គមត្រូវការកើតកើនប្រាក់ ជនជានមានសក្តិថ្នាក់ប្រពៃ។

៧- អានច្រើនចេះច្រើនកើនបញ្ញ សម្បូរវោហារថាវាងវៃ
វប្បធម៌អានថ្កានថ្លាថ្លៃ រស់ផុតរីងរៃព្រោះប្រាណថ្កាន។

៨- អំណានថ្លាថ្លៃក្រៃក្រៃលក្រាស់ នរៈក្មេងចាស់ច្បាស់គ្រប់ប្រាណ
ឆ្លាស់ឆ្លៀតលៃលករករៀនអាន ចំណេះចំណានបានគ្រប់គ្នា។

៩- ច្នេះទើបរាជរដ្ឋាភិបាល បណ្តុះបណ្តាលថ្នាលមាត៌
ទិវាអំណានកម្ពុជា ដប់មួយមីនាវេលាយស ។

១០- ចែងចប់សព្វគ្រប់ឈប់ចរចា ពរបួនប្រការថ្លាមិនមោះ
សម្បត្តិបីទៀតឆ្លៀតសង្គ្រោះ សូមសុខរួមរស់ឈ្មោះជាខ្មែរ៕

**ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ**

**«ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»**

**អបអរសាទរ ទិវាជាតិអំណានលើកទី៤ ១១ មីនា ២០១៩**

**យុវតី រិន ស៊ាវហ្វុង**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យសម្ដេចឪ ខេត្តតាកែវ*

**ចំណងជើងកំណាព្យ៖ «ផ្លែផ្កាអំណាន»**

(កំណាព្យបទ កាកគតិ)

១- ផ្កាពឹងសន្សើម ផ្ដល់ជាដង្ហើម ចាប់ផ្ដើមស្រស់ថ្លា
មេឃភ្លឺស្រឡះ ពឹងសុរិយា ចំណេះប្រាជ្ញា
ទីពឹងអំណាន។

២- អានច្បាប់វិន័យ គម្ពីរពិជ័យ លកលៃតាមដាន
កាសែតព័ត៌មាន រៀបរៀងរៀនអាន ភាសាជាតិថ្កាន
អានអក្សរសាស្ត្រ។

៣- ជំនាញរាប់ពាន់ រៀនអានរួសរាន់ គ្រប់គ្រាន់ប្ដូរផ្លាស់
បច្ចេកវិទ្យា មានច្រើនក្រៃក្រាស់ វិធីប្រើប្រាស់
អានច្បាស់យល់ការ។

៤- មត្តេយ្យឧត្តម រៀនអានរៀបចំ សន្សំប្រាជ្ញា
អានបានត្រឹមត្រូវ តម្រូវទីផ្សារ តាមទាន់ហេតុការណ៍
នៃសកលលោក។

៥- អានមួយជីវិត កើតកើនគំនិត ជីវិតជ័យជោគ
អានជាប្រចាំ ដូចថ្នាំកែរោគ អានហើយសំយោគ
ផុតរោគងងឹត។

៦- ចេះអក្ខរា ពាក្យពេចន៍ភាសា រីកប្រាជ្ញាពិត
បច្ចេកវិទ្យា ឆ្នៃជាគំនិត បំណិនជីវិត
ពិតជាចំណាប់។

៧- ជំនាញចំណេះ ធ្វើតាមតម្រិះ ចេះតាមតម្រាប់
ការងារតូចធំ ផ្ដុំតាមលំដាប់ អានចេះយល់ឆាប់
ក្បួនច្បាប់អំណាន។

៨- សំយោគវប្បធម៌ រក្សាឈាមជ័រ ជាតិជាសញ្ញាណ
ទ្រទ្រង់រុងរឿង ជាតិរីកថ្កើងថ្កាន ដូចសូរ្យកាន្ត
បានភ្លឺថ្លៃថ្លា។

៩- សតវត្សម្ភៃមួយ អំណានលើកស្ទួយ លាស់ត្រួយផ្លែផ្កា
កើតកើនគុណវុឌ្ឍ មោះមុតបញ្ញា អំណានសិក្សា
ពេញមួយជីវិត៕

## ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៤ ១១ មីនា ២០១៩

### យុវជន ហេង ស៊ីវម៉ា

ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ចរិយាវង្ស ខេត្តកែប

**ចំណងជើងកំណាព្យ៖ «អំណានជាយានឈានទៅភាពជោគជ័យ»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- សូរសងចែងចាំងភ្លឺដូចខែ លើផែនដីខ្មែរស្រស់សោភា
ផ្តល់សុខក្សេមក្សាន្តដល់បុត្រភ្វា ជ្រកក្រោមពសុធាដ៏ថ្លៃថ្លា។

២- ឯការអានប្រៀបបាននឹងថ្នាំ ដែលជួយផ្សះផ្សាំដល់កាយា
អានច្រើនបង្កើនភាពហានក្លា ដោះស្រាយបញ្ហារាល់បែបបទ។

៣- ចំណេះកើតមកពីអំណាន ជួយមនុស្សគ្រប់ប្រាណបានប្រាកដ
ជំនួយការរៀនឱ្យម៉ដ្ឋចត់ វិជ្ជាជាផ្នត់គំនិតថ្លៃ។

៤- អំណានជាយានឈានទៅរក នាំជ័យនាំជចោគល្អពេកក
ជាក្បួនតម្រាមានតម្ល អាចរកកម្រៃមហាសាល។

៥- អានច្រើនចេះច្រើនកើនពីទាប ឱ្យសន្តិភាពបានជាថ្នាល
ប្រស់ព្រំមនុស្សយើងហើយព្យាបាល នេះជាកម្រាលដ៏ប្រពៃ។

៦- ការអានបណ្តុះភាពថ្កានថ្កើង អាចជួយតម្កើងពាក្យពេចន៍ន័យ
ដែលជាកំណប់សមលើសន បានស្ថិតលើដីកម្ពុជា។

៧- ហេតុនេះកូនចៅចូរខំថ វប្បធម៌ខ្មែរសុខប្រជា
ឱ្យបានក្តីសុខគ្រប់ៗគ្នា ចេះជួយគ្រប់គ្រាមិនឆ្ងាយឡើយ។

៨- ជនរួមជាតិអើយប្រឹងខ្មីឃ្មាត យុវជនខ្មែរកុំកន្តើយ
ខេមរាជាជាតិថ្កើងថ្កានហើយ ថែឱ្យដល់ត្រើយតរៀងទៅ៕

អំណាន READING